**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ២០២ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## អត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រមក/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៨/០១០ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩១២/០០៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិជនពិការ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ២៩៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ
- បានឃើញអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ១៤៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ២៤៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការបង្កើតមូលនិធិហិរញ្ញប្បទានគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីយន្តការ និងនីតិវិធីអត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ដើម្បី÷

១. រៀបចំ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យអត្តសញ្ញាណកម្មពិការភាព ឱ្យមានបទដ្ឋានរួមមួយប្រកបដោយសង្គតិភាព តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងពិការភាព សម្រាប់ជាមូលដ្ឋានកំណត់ក្រុមគោលដៅជនមានពិការភាព ក្នុងការលើកកម្ពស់ជីវភាព ការទទួលបានសេវាសង្គម ការអភិវឌ្ឍដល់ជនមានពិការភាព និងប្រើប្រាស់ជាទិន្នន័យសម្រាប់កំណត់ក្រុមគោលដៅរបស់កម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ក្នុងប្រព័ន្ធគាំពារសង្គម។

២. ផ្តល់បណ្ណសម្គាល់ជនមានពិការភាព ដើម្បីបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាពក្នុងការទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គម និងសេវាសង្គមផ្សេងទៀត ប្រកបដោយសមធម៌ និងបរិយាបន្ន ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**មាត្រា២.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះជនមានពិការភាព ក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.-**

វាក្យសព្ទសំខាន់ៗ ក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចខាងក្រោម÷

- **ជនមានពិការភាព÷** សំដៅដល់ជនទាំងឡាយណាដែលមានវិកលសម្បទាផ្នែករាងកាយ ផ្លូវចិត្ត បញ្ញាស្មារតី ឬញ្ញាណដឹងអចិន្ត្រៃយ៍ ដែលនៅពេលជួបឧបសគ្គនានាអាចរារាំងដល់ពួកគេក្នុងការចូលរួមពេញលេញ និងមានប្រសិទ្ធភាព នៅក្នុងសង្គមដោយស្មើភាពជាមួយអ្នកដទៃ។
- **អត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន÷** សំដៅដល់ការកំណត់ស្ថានភាពជនមានពិការភាព ដែលរួមមានស្ថានភាពបុគ្គលពាក់ព័ន្ធនឹងអាយុ ភេទ និងស្ថានភាពគ្រួសារ ស្ថានភាពពិការភាពពាក់ព័ន្ធនឹងប្រភេទ កម្រិតពិការភាព និងតម្រូវការសេវា និងបរិស្ថានរស់នៅ ដូចជាជាសុកវត្ថុ និងជាសុកសមរម្យ ស្របទៅតាមលក្ខណៈវិនិច្ឆ័យតាមប្រភេទ និងកម្រិតពិការភាព។
- **បណ្ណសម្គាល់ជនមានពិការភាព÷** សំដៅដល់បណ្ណដែលផ្តល់ជូនជនមានពិការភាព ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំពោះជនមានពិការភាពទាំងឡាយណាដែលបានចូលរួម និងវាយតម្លៃ តាមរយៈអត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន។
- **ពិការភាពអចិន្ត្រៃយ៍÷** សំដៅដល់លក្ខខណ្ឌបុគ្គលម្នាក់មានពិការភាពដែលមិនអាចត្រលប់មកភាពប្រក្រតីវិញបាន ចាប់ពី ៦ខែឡើង។

## ជំពូកទី២
## នីតិវិធីអត្តសញ្ញាណកម្ម

**មាត្រា៤.-**

នីតិវិធីអត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ត្រូវអនុវត្តតាមដំណើរការដូចខាងក្រោម÷

- ជនមានពិការភាព ឬអាណាព្យាបាល ឬអ្នកតំណាងស្របច្បាប់ ដាក់ពាក្យស្នើសុំអត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន នៅឃុំ សង្កាត់ ដែលខ្លួនរស់នៅ។
- រដ្ឋបាលឃុំ សង្កាត់ ត្រូវប្រជុំណែនាំ និងសម្របសម្រួលជាមួយមេភូមិ ដើម្បីរៀបចំទិន្នន័យពិការភាពទូទៅ និងសម្ភាសជនមានពិការភាពតាមភូមិ ឬខ្នងផ្ទះ និងបញ្ចូលទិន្នន័យក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងពិការភាពទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត។
- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យឱ្យបានត្រឹមត្រូវ និងបញ្ជូនទិន្នន័យអត្តសញ្ញាណកម្មពិការភាពទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្នើសុំបណ្ណសម្គាល់ជនមានពិការភាព។

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងអនុម័តទិន្នន័យ បោះពុម្ពបណ្ណ និងផ្តល់បណ្ណសម្គាល់ជនមានពិការភាព។

នីតិវិធីលម្អិតនៃអត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា៥.-**

នីតិវិធីធ្វើបច្ចុប្បន្នភាពស្ថានភាពពិការភាព ត្រូវអនុវត្តតាមដំណើរការ ដូចខាងក្រោម÷

- ជនមានពិការភាព ឬអាណាព្យាបាល ឬអ្នកតំណាងស្របច្បាប់ អាចស្នើសុំធ្វើបច្ចុប្បន្នភាពស្ថានភាពពិការភាព នៅឃុំ សង្កាត់ ដែលខ្លួនរស់នៅ។
- រដ្ឋបាលឃុំ សង្កាត់ សម្ភាសជនមានពិការភាព និងបញ្ជូនទិន្នន័យ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងពិការភាពទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត។
- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវត្រួតពិនិត្យ និងផ្ទៀងទិន្នន័យឱ្យបានត្រឹមត្រូវ និងបញ្ជូនទិន្នន័យអត្តសញ្ញាណកម្មពិការភាព ទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្នើសុំបណ្ណសម្គាល់ជនមានពិការភាពថ្មី។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងអនុម័តទិន្នន័យ បោះពុម្ពបណ្ណ និងផ្តល់បណ្ណសម្គាល់ជនមានពិការភាពថ្មី។

នីតិវិធីលម្អិតនៃការធ្វើបច្ចុប្បន្នភាពស្ថានភាពពិការភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា៦.-**

ករណីបណ្ណសម្គាល់ជនមានពិការភាពខុសព័ត៌មាន បាត់បង់ ឬខូច ត្រូវអនុវត្តតាមដំណើរការស្នើសុំបណ្ណសម្គាល់ជនមានពិការភាពឡើងវិញ ស្របតាមនីតិវិធីដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ។

ករណីបណ្ណសម្គាល់ជនមានពិការភាពខុសព័ត៌មាន ជនមានពិការភាព អាណាព្យាបាល ឬអ្នកតំណាងស្របច្បាប់ ត្រូវភ្ជាប់មកជាមួយនូវបណ្ណសម្គាល់ជនមានពិការភាពដែលខុសនោះ ដើម្បីទទួលបាននូវបណ្ណសម្គាល់ជនមានពិការភាពថ្មីដែលត្រឹមត្រូវ។

ករណីបណ្ណសម្គាល់ជនមានពិការភាពបាត់បង់ ឬខូចខាត ជនមានពិការភាព អាណាព្យាបាល ឬអ្នកតំណាងស្របច្បាប់ ត្រូវដាក់ពាក្យស្នើសុំដោយភ្ជាប់មកជាមួយនូវឯកសារ ឬភស្តុតាង បើមាន ដើម្បីស្នើសុំបណ្ណទុតិយតា។

នីតិវិធីលម្អិតនៃការផ្តល់បណ្ណទុតិយតា និងបណ្ណសម្គាល់ជនមានពិការភាពថ្មី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។



៤៩

**មាត្រា៧.-**

ជនមានពិការភាព ដែលចូលរួមសម្ភាសក្នុងការកំណត់អត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ត្រូវបានវាយតម្លៃតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងពិការភាព ដើម្បីទទួលបានបណ្ណសម្គាល់ជនមានពិការភាព ទៅតាមប្រភេទ និងកម្រិតពិការភាព។

ប្រភេទពិការភាព ចែកចេញជា ៥ ប្រភេទ រួមមាន÷

- ពិការភាពកាយសម្បទា
- ពិការភាពញាណដឹង
- ពិការភាពសតិបញ្ញា
- ពិការភាពផ្លូវចិត្ត
- ពិការភាពផ្សេងៗ

ប្រភេទពិការភាពនីមួយៗ ចែកចេញជា ៣ កម្រិត រួមមាន÷

- កម្រិត១ (កម្រិតធ្ងន់បំផុត និងធ្ងន់)
- កម្រិត២ (កម្រិតមធ្យម)
- កម្រិត៣ (កម្រិតស្រាល)។

នីតិវិធីវាយតម្លៃប្រភេទ និងកម្រិតពិការភាព ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា៨.-**

បណ្ណសម្គាល់ជនមានពិការភាព មានសុពលភាពជាអចិន្ត្រៃយ៍ លើកលែងតែជនមានពិការភាពដែលត្រូវបានដកចេញពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងពិការភាព ក្នុងករណី÷

- ទទួលមរណភាព
- ចាកចេញពីកម្មវិធីដោយស្ម័គ្រចិត្ត
- មិនមានពិការភាពអចិន្ត្រៃយ៍
- ក្លែងបន្លំបណ្ណសម្គាល់ជនមានពិការភាព។

នីតិវិធីលម្អិតនៃការដកចេញជនមានពិការភាពពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងពិការភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូកទី៣
## ប្រភពធនធាន

**មាត្រា៩.-**

ថវិកាសម្រាប់ដំណើរការអនុវត្តអត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ត្រូវហិរញ្ញប្បទានដោយថវិកាជាតិ តាមរយៈមូលនិធិហិរញ្ញប្បទានគាំពារសង្គម និងប្រភពស្របច្បាប់ផ្សេងទៀត។

ថវិកាសម្រាប់ដំណើរការអនុវត្តអត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ត្រូវគ្រោង និងកត់ត្រានៅក្នុងក្របខណ្ឌនៃកញ្ចប់ថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូកទី៤
## តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន

**មាត្រា១០**.-

ក្រុមប្រឹក្សាជាតិគាំពារសង្គម មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- សម្របសម្រួលកម្រិតគោលនយោបាយ រវាងក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ក្នុងក្របខណ្ឌកិច្ចគាំពារសង្គម
- ផ្តល់ការតម្រង់ទិសផ្នែកគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងក្របខណ្ឌកិច្ចគាំពារសង្គម
- តាមដាន និងវាយតម្លៃការអនុវត្តអត្តសញ្ញាណកម្មពិការភាព។

**មាត្រា១១**.-

ក្រុមប្រឹក្សាសកម្មភាពជនពិការ មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- សម្របសម្រួលកម្រិតគោលនយោបាយ រវាងក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ក្នុងវិស័យពិការភាព
- ផ្តល់ការតម្រង់ទិសផ្នែកគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធវិស័យពិការភាព
- តាមដាន និងវាយតម្លៃការអនុវត្តអត្តសញ្ញាណកម្មពិការភាព។

**មាត្រា១២**.-

អត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ត្រូវដឹកនាំអនុវត្តដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមានការចូលរួមគាំទ្រពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- ដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការអនុវត្តអត្តសញ្ញាណកម្មពិការភាព
- រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់អត្តសញ្ញាណកម្មពិការភាព
- រៀបចំលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ការអនុវត្តអត្តសញ្ញាណកម្មពិការភាព
- កសាងសមត្ថភាព និងគាំទ្របច្ចេកទេសដល់មន្ត្រីទទួលបន្ទុក
- ផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីអត្តសញ្ញាណកម្មពិការភាព ដល់មន្ត្រី ភាគីពាក់ព័ន្ធ ជនមានពិការភាព និងសាធារណជន
- បោះពុម្ព និងផ្តល់បណ្ណសម្គាល់ជនមានពិការភាព ជូនជនមានពិការភាព
- រៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងពិការភាព
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមនានា ពាក់ព័ន្ធនឹងអត្តសញ្ញាណកម្មពិការភាព
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តអត្តសញ្ញាណកម្មពិការភាព។



៥

**មាត្រា១៣.-**

ក្រសួងមហាផ្ទៃ មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- គាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តអត្តសញ្ញាណកម្មពិការភាព
- សហការក្នុងការកសាងសមត្ថភាព និងគាំទ្របច្ចេកទេសដល់មន្ត្រីទទួលបន្ទុក
- ចូលរួមផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងដល់មន្ត្រី ភាគីពាក់ព័ន្ធ ជនមានពិការភាព និងសាធារណជន។

**មាត្រា១៤.-**

ក្រសួងផែនការ មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- សហការ និងគាំទ្រការអនុវត្តអត្តសញ្ញាណកម្មពិការភាព
- បន្ស៊ីទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងពិការភាព ជាមួយនឹងប្រព័ន្ធទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។

**មាត្រា១៥.-**

ក្រសួងសុខាភិបាល មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- គាំទ្រ និងសម្របសម្រួលមូលដ្ឋានសុខាភិបាលសាធារណៈ ក្នុងការចេញលិខិតបញ្ជាក់ស្ថានភាពសុខភាព តាមការស្នើសុំរបស់ជនមានពិការភាព
- បន្ស៊ីទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងពិការភាព ជាមួយនឹងប្រព័ន្ធទិន្នន័យរបស់ក្រសួងសុខាភិបាល តាមការចាំបាច់
- ចូលរួមផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងដល់មន្ត្រី ភាគីពាក់ព័ន្ធ ជនមានពិការភាព និងសាធារណជន។

**មាត្រា១៦.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- ត្រួតពិនិត្យ ផ្តល់យោបល់ និងសម្រេចលើគម្រោងថវិកាពាក់ព័ន្ធនឹងអត្តសញ្ញាណកម្មពិការភាព
- សម្របសម្រួលការវិភាជថវិកាសម្រាប់ការអនុវត្តអត្តសញ្ញាណកម្មពិការភាព។

**មាត្រា១៧.-**

រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- សម្របសម្រួលជាមួយមន្ទីរ ការិយាល័យ និងអង្គភាពពាក់ព័ន្ធ ក្នុងការគាំទ្ររដ្ឋបាលឃុំ សង្កាត់
- សហការក្នុងការកសាងសមត្ថភាព និងគាំទ្របច្ចេកទេសដល់មន្ត្រីទទួលបន្ទុក
- ចូលរួមផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងដល់មន្ត្រី ភាគីពាក់ព័ន្ធ ជនមានពិការភាព និងសាធារណជន
- សម្របសម្រួល និងចូលរួមដោះស្រាយបញ្ហាប្រឈមនានា ពាក់ព័ន្ធនឹងអត្តសញ្ញាណកម្មពិការភាព។

**មាត្រា១៨.-**

រដ្ឋបាលឃុំ សង្កាត់ មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- សម្ភាសជនមានពិការភាព ប្រមូល និងបញ្ចូលទិន្នន័យអត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងពិការភាព
- ធ្វើបច្ចុប្បន្នភាពអត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន តាមការកំណត់ និងតាមការស្នើសុំ ជាប្រចាំ
- បញ្ចូលសកម្មភាពអត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋានទៅក្នុងផែនការអភិវឌ្ឍរយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល របស់រដ្ឋបាលឃុំ សង្កាត់
- ផ្សព្វផ្សាយអំពីអត្តសញ្ញាណកម្មពិការភាពដល់ជនមានពិការភាព សាធារណជន និងភាគីពាក់ព័ន្ធ
- សម្របសម្រួលផ្តល់បណ្ណសម្គាល់ជនមានពិការភាពដល់ជនមានពិការភាព នៅតាមមូលដ្ឋានរបស់ខ្លួន
- តាមដាន ត្រួតពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានា ពាក់ព័ន្ធនឹងអត្តសញ្ញាណកម្មពិការភាព។

## ជំពូកទី៥
## ការគ្រប់គ្រងនិងការប្រើប្រាស់ទិន្នន័យ និងបណ្ណសម្គាល់ជនមានពិការភាព

**មាត្រា១៩.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានសមត្ថកិច្ចចងក្រង គ្រប់គ្រង ផ្សព្វផ្សាយ និងចែកចាយទិន្នន័យអត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងពិការភាព ដោយរក្សាឯកជនភាពរបស់ជនមានពិការភាព។

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងពិការភាព ត្រូវតភ្ជាប់ ធ្វើសមកាលកម្ម និងបច្ចុប្បន្នកម្មទិន្នន័យជាមួយនឹងមូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម តាមរយៈលេខសម្គាល់គាំពារសង្គម។

**មាត្រា២០.-**

ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសហគមន៍មូលដ្ឋាន អាចស្នើសុំទិន្នន័យអត្តសញ្ញាណកម្មពិការភាពពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា យកទៅប្រើប្រាស់ ដោយធានាឱ្យបាននូវការរក្សាឯកជនភាពរបស់ជនមានពិការភាព និងមិនត្រូវប្រើប្រាស់ទិន្នន័យប្រាសចាកពីកម្មវត្ថុនៃការស្នើសុំឡើយ។

**មាត្រា២១.-**

ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសហគមន៍មូលដ្ឋាន ត្រូវទទួលស្គាល់ និងប្រើប្រាស់បណ្ណសម្គាល់ជនមានពិការភាពជាមូលដ្ឋាន ដើម្បីលើកកម្ពស់សុខុមាលភាព និងការអភិវឌ្ឍដល់ជនមានពិការភាព ប្រកបដោយបរិយាបន្ន ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៦
## វិធានការរដ្ឋបាល

**មាត្រា២២.-**

ជនណាក្លែងបន្លំបណ្ណសម្គាល់ជនមានពិការភាព ឬទិន្នន័យអត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ត្រូវទទួលខុសត្រូវ ចំពោះមុខច្បាប់ជាធរមាន។

## ជំពូកទី៧
## ការដោះស្រាយវិវាទ ឬបណ្តឹង

**មាត្រា២៣.-**

វិវាទ ឬបណ្តឹងដែលពាក់ព័ន្ធនឹងការអនុវត្តអត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ត្រូវដោះស្រាយក្នុងកម្រិតឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្ត។ ក្នុងករណីមិនអាចដោះស្រាយបាន វិវាទ ឬបណ្តឹងនោះ ត្រូវបន្តនីតិវិធីទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬប្តឹងទៅតុលាការ។

នីតិវិធីលម្អិតនៃការដោះស្រាយវិវាទ ឬបណ្តឹងក្នុងការអនុវត្តអត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា២៤.-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណា ដែលចែងអំពីការវាយតម្លៃប្រភេទ ថ្នាក់ពិការ ចំពោះយោធិនពិការ និងអតីតយោធិនពិការ ដែលកំពុងនៅជាធរមាន ត្រូវមានអានុភាពអនុវត្តបន្ត ប្រកបដោយប្រសិទ្ធភាព។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា២៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ៚

ថ្ងៃព្រហ ២កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០២៣ ✓

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច** |
| **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **អតីតយុទ្ធជន និងយុវនីតិសម្បទា** |
| **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** | **វង សូត** |

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ